**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**ខេត្តកំពង់ចាម**

លេខៈ ១៧១/២០ ក.ប/ក.ច

**ជម្រាបមក**
**លោកនាយក អៅលែន ដេនីម (ខេមបូឌា) ខូអិលធីឌី**

**កម្មវត្ថុ** ៖ ការអនុញ្ញាតព្យួរកិច្ចសន្យាការងារកម្មករនិយោជិត
**យោង** ៖ លិខិតលេខ២០០៤២១១៤៥២ចុះថ្ងៃទី២១ខែមេសាឆ្នាំ២០២០ របស់ក្រុមហ៊ុន អៅលែន ដេនីម(ខេមបូឌា)ខូអិលធីឌី

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **លោកនាយក** ថា បន្ទាប់ពីបានពិនិត្យលើការស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិត ក្រសួងសម្រេចអនុញ្ញាតឱ្យព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ៨៣នាក់ (ស្រី ៧១នាក់) ក្នុងចំនួនកម្មករនិយោជិតសរុប ៨៦នាក់ (ស្រី៧២នាក់) រយៈពេលចំនួន ២០ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២០។ ដើម្បីជួយសម្រួលដល់ជីវភាពប្រចាំថ្ងៃរបស់កម្មករនិយោជិតក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារនេះ **លោកនាយក** ត្រូវអនុវត្តការបើកប្រាក់ឧបត្ថម្ភរបស់ខ្លួនឱ្យបានត្រឹមត្រូវតាមនីតិវិធីទូទាត់និងចំនួនដែលបានព្រមព្រៀងគ្នា។

ក្នុងករណី **លោកនាយក** ចង់ដំណើរការផលិតកម្ម ឬអាជីវកម្ម មុនកាលបរិច្ឆេទនៃការបញ្ចប់ការព្យួរកិច្ចសន្យាការងារ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឱ្យបានយ៉ាងតិច ២ថ្ងៃ (នៃថ្ងៃធ្វើការ) មុនថ្ងៃចូលធ្វើការ។

អាស្រ័យដូចនេះ សូម **លោកនាយក** បិទផ្សាយនូវលិខិតនេះ ជូនកម្មករនិយោជិតឱ្យបានជ្រាបគ្រប់ៗគ្នា។

សូម **លោកនាយក** ទទួលនូវសេចក្តីរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

ថ្ងៃ អង្គារ ៧កើត ខែ ពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦៣
កំពង់ចាម ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ២០២០
**ត.ប. រដ្ឋមន្ត្រី**
**ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**ចេង ហ៊ាង**

ចម្លងជូនៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងទេសចរណ៍ (សម្រាប់វិស័យទេសចរណ៍)
- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ក្រសួងរ៉ែ និងថាមពល
- ធនាគារជាតិនៃកម្ពុជា
- អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បេឡាជាតិសន្តិសុខសង្គម
- ទីភ្នាក់ងារជាតិមុខរបរ និងការងារ
- រដ្ឋបាលខេត្ត